# ក្រសួងធម្មការនិងសាសនា
## Ministry of Cult and Religion

# ថវិកាពលរដ្ឋ ឆ្នាំ២០២៦
## Citizen Budget Fiscal Year 2026



**អាសយដ្ឋាន ៖** វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរស័ព្ទលេខ ៖** (៨៥៥-២៣) ៧២២ ៦៩
**អ៊ីម៉ែល ៖** info@mocar.gov.kh
**គេហទំព័រ ៖** www.mocar.gov.kh

### ១. សេចក្តីផ្តើម

**ថវិកាសង្ខេប** គឺជាឯកសារផ្សព្វផ្សាយព័ត៌មានថវិកាប្រចាំឆ្នាំជូនដល់ភាគីពាក់ព័ន្ធ និងអ្នកទទួលផលពីសេវាសាធារណៈដែលផ្តល់ដោយក្រសួងធម្មការនិងសាសនា។

### ២. បេសកកម្ម និងភារកិច្ច

ក្រសួងធម្មការនិងសាសនា បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យធម្មការនិងសាសនា និងទទួលខុសត្រូវផ្តល់សេវាសាធារណៈចម្បងៗ ដែលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តមានដូចខាងក្រោម៖

- ការលើកកម្ពស់សាសនារបស់រដ្ឋ
- ការលើកកម្ពស់សីលធម៌សង្គម
- ការរក្សាសុខដុមនីយកម្មសាសនា
- ការពង្រឹងគុណភាពវិស័យពុទ្ធិកសិក្សាគ្រប់កម្រិត
- ការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្ស

### ៣. គោលបំណងគោលនយោបាយ

ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំពោរពេញ ដោយថាមពល និងប្រកបដោយឆន្ទៈក្លៀវក្លារបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពនៅកម្ពុជា** សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រសួងធម្មការនិងសាសនា បាននឹងកំពុងបន្តអនុវត្តគោលនយោបាយ "**លើកកម្ពស់សាសនារបស់រដ្ឋ តម្លៃសីលធម៌សង្គម និងសុខដុមនីយកម្មសាសនា**" ដោយផ្អែកលើផែនការយុទ្ធសាស្ត្រចំនួន៥ របស់ក្រសួងរួមមាន៖ **ការលើកកម្ពស់សាសនារបស់រដ្ឋ ការលើកកម្ពស់សីលធម៌សង្គម ការរក្សាសុខដុមនីយកម្មសាសនា ការពង្រឹងគុណភាពវិស័យពុទ្ធិកសិក្សាគ្រប់កម្រិត និងការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្ស**។

ដើម្បីអនុវត្តគោលនយោបាយ ខាងលើឱ្យទទួលបានជោគជ័យក្រសួងធម្មការនិងសាសនា បានរៀបចំរចនាសម្ព័ន្ធកម្មវិធីចំនួន ៣ ដូចខាងក្រោម៖

| ឈ្មោះកម្មវិធី | អនុកម្មវិធី | ចង្កោមសកម្មភាព |
|---|---|---|
| កម្មវិធីទី១៖ ការរក្សាសុខដុមនីយកម្មសាសនា | ៤ | ៣២ |
| កម្មវិធីទី២៖ ការអប់រំវិស័យពុទ្ធិកសិក្សា | ៣ | ៣៣ |
| កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | ៤ | ៣៣ |
| សរុបអនុកម្មវិធី និងចង្កោមសកម្មភាព | ១១ | ៩៨ |

យោងតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៦ ក្រសួងធម្មការនិងសាសនា បានទទួលឥណទានថវិកាសរុបចំនួន **៧៧ ៣៥៩.៥** លានរៀល និងបានកំណត់នូវសូចនាករគន្លឹះដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗ ដូចខាងក្រោម៖

### កម្មវិធីទី១ ៖ ការរក្សាសុខដុមនីយកម្មសាសនា

**គោលបំណងកម្មវិធី៖** លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋលើកកម្ពស់តម្លៃសីលធម៌សង្គម និងលើកស្ទួយសេរីភាពខាងជំនឿសាសនា និងរក្សាឱ្យបាននូវសុខដុមនីយកម្មសាសនា ដើម្បីការពារ ថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម កសាងធនធានមនុស្សប្រកបដោយសីលធម៌ ចរិយាធម៌ និងការអភិវឌ្ឍសង្គម។

**សូចនាករលទ្ធផលចុងក្រោយ (KPI)**

| | |
|---|---|
| KPI-101 | ភាគរយនៃបូជនីយដ្ឋានសាសនាត្រូវបានគ្រប់គ្រងប្រកបដោយសុខដុមរមនា |
| KPI-102 | ចំនួនព្រះសង្ឃ អាចារ្យ អាចារិនី ពុទ្ធបរិស័ទ បានទទួលការបណ្តុះបណ្តាលតួនាទី ភារកិច្ច និងពង្រឹងសមត្ថភាពការគ្រប់គ្រង់ប្រកបដោយចីរភាព |

អនុកម្មវិធីទី១.១៖ ការថែរក្សាគុណតម្លៃព្រះពុទ្ធសាសនា
អនុកម្មវិធីទី១.២៖ ការស្រាវជ្រាវ ចងក្រង អភិរក្ស និងផ្សព្វផ្សាយឯកសារប្រពៃណីទំនៀមទម្លាប់ វប្បធម៌សាសនា
អនុកម្មវិធីទី១.៣៖ ការលើកកម្ពស់សេរីភាពខាងជំនឿ សាសនា ប្រកបដោយសុខដុមនីយកម្ម
អនុកម្មវិធីទី១.៤៖ សេវាគាំទ្រការរក្សាសុខដុមនីយកម្មសាសនា របស់មន្ទីរជំនាញរាជធានី ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី១** ទឹកប្រាក់សរុបចំនួន ៩ ១២៥,៨ លានរៀល

**រូបភាពទី១៖ ថវិកាកម្មវិធីទី១ ការរក្សាសុខដុមនីយកម្មសាសនា** *(ឯកតា៖ លានរៀល)*



## កម្មវិធីទី២ ៖ ការអប់រំវិស័យពុទ្ធិកសិក្សា

**គោលបំណងកម្មវិធី៖** លើកកម្ពស់ចំណេះដឹងផ្នែកពុទ្ធចក្រ និងអាណាចក្រ ក្នុងការកសាងធនធានមនុស្សប្រកបដោយសមត្ថភាព សីលធម៌ និងចរិយាធម៌។

**សូចនាករលទ្ធផលចុងក្រោយ (KPI)**

| | |
|---|---|
| KPI-201 | ភាគរយសមណសិស្ស-និស្សិតនិងសិស្ស-និស្សិតដែលបានបញ្ចប់ការសិក្សាគ្រប់កម្រិត |
| KPI-202 | ចំនួនសមណសិស្ស-និស្សិតនិងសិស្ស-និស្សិតបានទទួលការអប់រំគ្រប់កម្រិត |

អនុកម្មវិធីទី២.១៖ ការអប់រំពុទ្ធិកសិក្សាគ្រប់កម្រិត

អនុកម្មវិធីទី២.២៖ ការផ្តល់សេវាទ្រទ្រង់វិស័យពុទ្ធិកសិក្សា

អនុកម្មវិធីទី២.៣៖ សេវាគាំទ្រការអប់រំវិស័យពុទ្ធិកសិក្សា របស់មន្ទីរជំនាញរាជធានី ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី២** ទឹកប្រាក់សរុបចំនួន **៣៦ ១១៦,១** លានរៀល

**រូបភាពទី២៖ ថវិកាកម្មវិធីទី២ ការអប់រំវិស័យពុទ្ធិកសិក្សា** *(ឯកតា៖ លានរៀល)*




## កម្មវិធីទី៣៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

**គោលបំណងកម្មវិធី៖** កសាងរដ្ឋបាលសាធារណៈដែលមានសមត្ថភាពខ្ពស់ខ្លាំងវៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។

**សូចនាករលទ្ធផលចុងក្រោយ (KPI)**

| | |
|---|---|
| KPI-301 | ចំនួនរចនាសម្ព័ន្ធអង្គភាព ដើម្បីគាំទ្រស្ថាប័ន |
| KPI-302 | ភាពទាន់ពេលវេលានៃការផ្តល់សេវារដ្ឋបាលនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព |
| KPI-303 | កិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិត្រូវបានលើកកម្ពស់ |

អនុកម្មវិធីទី៣.១៖ ការផ្តល់សេវាគាំទ្រទូទៅ

អនុកម្មវិធីទី៣.២៖ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងកិច្ចការនីតិកម្ម

អនុកម្មវិធីទី៣.៣៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង

អនុកម្មវិធីទី៣.៤៖ សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅរបស់មន្ទីរជំនាញរាជធានី ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី៣** ទឹកប្រាក់សរុបចំនួន **៣២ ១១៧,៦** លានរៀល

**រូបភាពទី៣៖ ថវិកាកម្មវិធីទី៣ ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ** *(ឯកតា៖ លានរៀល)*

